# ឃ

**ឃ** ព្យញ្ជនៈទី ៤ ក្នុងវគ្គទី ១ ជាកណ្ឋជៈ មានសំ-ឡេងក្នុងបំពង់ក ។ ជាធនិត-ឃោសៈ គាត់សំស្រូវធនិតជាសិ មានសំឡេងជា *ឃ្ហ:* ។ សម្រាប់ភាសាខ្មែរ, ផ្សំនឹងស្រៈ *អ អា អិ អី ។ល។ អុំ អំ អាំ អះ* សំឡេង *អ៊ិ អ៊ា អ៊ី អ៊ឹ ។ល។ អុំ អំ អាំ អះ* ជា *ឃ ឃា ឃិ ឃី ។ល។ ឃុំ ឃំ ឃាំ ឃះ* ។

**ឃរណី** (ឃៈ-រៈ-នី) *ន.* (បា.; សំ. *គ្ឫហិណី*) ស្ត្រីជាម្ចាស់ផ្ទះ, មេផ្ទះ, ប្រពន្ធ (ព. ក.) ។

**ឃរមូល** (ឃៈ-រៈ-) *ន.* (បា.; សំ. *គ្ឫហមូល*) ឫសសំណាក់ផ្ទះ ។

**ឃរាវាស** (ឃៈ-រា-) *ន.* (បា.; សំ. *គ្ឫហាវាស*) ការនៅគ្រប់គ្រងផ្ទះ; អ្នកនៅគ្រប់គ្រងផ្ទះ (ម. ព. *គ្រឹហាវាស*, *គ្រហស្ថ* ផង) ។

**ឃាង** *កិ.* និយាយជបំបាត់កាត់ប្រយោជន៍គេ (មិនសូវប្រើ) ។

**ឃាត** *ន.* (សំ. បា.) ការសម្លាប់, ការបំបាត់ជីវិត, ការបៀតបៀន, ការធ្វើទុក្ខទោស : *ធ្វើឃាតជាប់ម្នាក់* ។

**ឃាត់** *កិ.* (សំ. បា. *ឃដ៌, ឃាត* "បៀតបៀន; ប្រហារ; កាត់; ប្រព្រឹត្ត, ធ្វើ, ទំព្រឹង ...") ហាម; ទប់; កាត់ : *ឃាត់កូនកុំឲ្យលេងភ្លោះភ្លា, ឃាត់គ្រឿងឲ្យក្រឡៃឈប់* ។ *ឃាត់កំហឹង* គឺទប់កំហឹង; *ឃាត់ចំណង់* គឺទប់ចំណង់ ។ (ម. ព. *ឃាត* ទៀតផង ។

**ឃាតក:** (ឃា-តៈ-កៈ) *ន.* (បា. *ឃាតក*) អ្នកធ្វើឃាត, អ្នកសម្លាប់ ។

**ឃាតកម្ម** (ឃាតៈ-កាំ) *ន.* (បា.) អំពើនៃការសម្លាប់, អំពើសម្លាប់, អំពើបៀតបៀន ។

**ឃិនឆាយ ឬ ឃុយឆាយ** *ន.* (ចិ.) ឈ្មោះបន្លែជាតិមួយយ៉ាង សណ្ឋានប្រហែលនឹងកំផ្លៀម តែស្លឹកធំជាងកំផ្លៀម ក្លិនក៏ខុសគ្នា ។

**ឃឹកៗ** *កិ.* សូរដោយលោតញ័រ តែលឮជំ ឬ សូរបើកដោយទប់មិនឲ្យលាន់ឮខ្លាំង (ម. ព. *គឃឹក* ផង) ។

**ឃឹម** *ន.* (ចិ.) ឈ្មោះគ្រឿងភ្លេងមួយយ៉ាង មានខ្សែធ្វើដោយលួស មានស្នូក ។



**ឃុន** *ន.* ទីតំណែងអ្នកមានបណ្ដាស័ក្តិទាបហួសជាង : *ឃុនគត្តិសម្បត្តិ ...* ។

**ឃុយឆាយ** *ន.* (ម. ព. *ឃិនឆាយ* ផង) ។

**ឃូរៗ** *កិ.* សូរឮរលំកើតដោយផ្ទុំ, ដោយលង់, ដោយបក់ : *ផ្ទុំឃូរៗ, សង់ភ្លើងឃូរៗ, ខ្យល់ឃូរៗ* ។

**ឃូសៗ** *កិ.* សូរឮពោលពោរ, ដោយព្ពកស្លូត (ម. ព. *គឃូស* ផង) ។

**ឃើញ** *កិ.* ធ្វើយល់រូបប្រាកដដោយភ្នែក : *ឃើញមនុស្សដើរច្រើននាក់* ។

**ឃៃក** *គុ.* ឬ *កិ. វិ.* គ្រាស៊ត, ខេៗ : *ទៅវិញឃៃក* គឺទៅវិញទទេ ឥតបានអ្វីសោះ (ម. ព. *គ្រាស៊ត* ផង) ។

**ឃោរ** *គុ.* (សំ. បា.) ខ្លាំង, កាចខ្លាំង, ឆ្អឹងខ្លាំង, គួរស្បើម : *ទីតឃោរ* គឺតឹងខ្លាំង ។ បុណណមានប្រើជា *ន.* ខ្លះ ដូចពាក្យថា *បុណ្យបាត់ផ្សៀតបាប លាភបាត់ផ្សៀតឃោរ* ។

**ឃោរឃៅ** *គុ.* ខ្លាំងក្រៃ, កាចខ្លាំងក្លា, ហៅហាន, អោះអុក, កាចខ្លាំងឥតមានមេត្តាប្រណី : *ចិត្តឃោរឃៅ, ពោរឃោរឃៅ* ។

**ឃោស ឬ ឃោសៈ** *ន.* (បា. *ឃោស* "សូរ, សំឡេងទឹកកង") ឈ្មោះព្យញ្ជនៈ ដែលមានសំឡេងទឹកកង មាន ២០ តួគឺ *គឃង, ជឈញ, ឌឍណ, ទធន, ពភម; យរលវហឡ;* និងស្រៈពេញតួទាំងអស់ ក៏រាប់បញ្ចូលក្នុងពួកពាក្យ *ឃោសៈ* ដែរ ។ ពាក្យផ្ទុយ *អឃោសៈ* ។

**ឃោសនា** (ឃោស្នា) *ន.* (បា.) សំដីទឹកកង, សំឡេងកងរំពង, ទីអឺងអាច; ការប្រកាស, ការស្រែកប្រកាសឮខ្លាំងៗ ផ្សាយដំណឹងឲ្យសាធារណជនដឹង, ការផ្សាយដំណឹងឲ្យឮសាយសុសសព្វគ្នា ។ ប្រើតាមទម្លាប់ចំពោះតែការប្រកាសអង្គាសវត្ថុផ្សេងៗ ធ្វើបុណ្យឲ្យទាន; ប្រើជា *ន.* ឬ *គុ.* ឬ *កិ.* ក៏បាន : *សេចក្តីឃោសនា, សំបុត្រឃោសនា; ភាពព្យឃោសនាចង្ហាន់, ឃោសនាចតុប្បច្ច័យ* (សរសេរក្លាយជា *ឃោស្នា* តាមសូរសំនៀងនិយាយក៏មាន: សរសេរបែបនេះ សម្រាប់ប្រើក្នុងកាព្យ, សរសេរត្រឹមត្រូវជា *ឃោសនា* ក. ចំ. *ឃោស្នា*) ។

**ឃោសនាការ** (—ស្នាកា ឬ —សៈនាកា) *ន.* (បា.) ឈ្មោះក្រសួងរដ្ឋមន្ត្រីមួយផ្នែក ខាងការផ្សាយដំណឹងផ្សេងៗ : *ក្រសួងឃោសនាការ* ។

**ឃោសាឃោសវិមុត្ត** (—សៈវិមុត) *ន.* (បា.) អក្សរៈដែលរួចផុតស្រឡះពីឃោសៈ និង អឃោសៈ គឺមិនមែនជាឃោសៈ ឬ អឃោសៈ បានដល់និគ្គហិត ( ំ ) ។

**ឃោស្នា** *ន.* (ម. ព. *ឃោសនា*) ។

**ឃុំ ១** កិ. ទាំងរក្សាមិនឲ្យទៅណាតាមតែចិត្ត: *ឃុំមនុស្សទោសក្នុងគុក* ។ ន. ដំណើរដែលឃុំ: *នៅក្នុងឃុំមិនទាន់រួចនៅឡើយ* ។

**ឃុំ ២** ន. ភូមិភាគអំណាចមេឃុំមួយ ដែលប្រជុំភូមិច្រើន ឬ តិចតាមបញ្ញត្តិរាជការរដ្ឋបាល: *មន្ត្រីឃុំ, មេឃុំ, ប្រាក់សម្រាប់ឃុំ* ។ ឥឡូវនេះប្រើថា *សង្កាត់*; មេឃុំហៅថា *ចៅសង្កាត់* ។

**ឃុំ ៣** គុ. ដែលនៅក្ដៅឧណ្ហៗ: *ទឹកឃុំ* (គ្រាមភាសា និយាយតាមទម្លាប់ដោយភូមិស្រុកខ្លះ) ។

**ឃាំង** កិ. រាំង, ស្កាត់ដំណើរ: *ឃាំងផ្លូវមិនឲ្យមនុស្សដើរ* ។ ម. *រាំង* ។

**ឃ្មើប** កិ. ឬ កិ. វិ. ឬ គុ. ញាក់ញោច, ឡើបដោយរលើប ឬ ដោយញាប់ញ័រ: *រលើបឃ្មើប, គាត់ដើរទៅឃើញបន្ទាលោតឃ្មើប; ដំណើរឃ្មើបៗ* (ម. ព. *ឃ្មើបៗ* ផង) ។

**ឃ្នង ១** ន. មេទាំងតែងសង្កត់ក្បាលបន្ទោលប្រកាស, បន្ទោលរបង: *ឃ្នងក្រោលក្របី* ។

**ឃ្នង ២** គុ. ក្រហើន, ប្រឡើសខុសច្បាប់, ច្រងេង: *មនុស្សឃ្នង, ឃ្នើសឃ្នង* ។ ន. ដំណើរប្រព្រឹត្តិល្មើស, ប្រឡើសគងលើច្បាប់: *សេចក្ដីឃ្នង* (ម. ព. *ឃ្នើសឃ្នង* ផង) ។

**ឃ្នាង** ន. គ្រឿងមានកាំទាំងមួយម្ខាង សម្រាប់ដាក់កមនុស្សទោស: *មនុស្សជាប់ឃ្នាង, នាយគុកឃុំទាញយកឃ្នាងទៅដាក់មនុស្សទោស* ។

**ឃ្នាប** ន. ប្រដាប់សម្រាប់ខាប: *ឃ្នាបកំពៅ* (ម. ព. *កំនាប* ផង) ។

**ឃ្នួស** ន. ប្រដាប់សម្រាប់ខួស: *ដែកឈើ ឬ ដែកស្កាន់ជាឃ្នួសគួសតម្រង់ជួង; បន្ទាត់ជាឃ្នួសគួសឲ្យមានស្នាមជាខ្សែត្រង់* ។ ព. ថ្ម. *ស្នួស* គឺស្នាម ដែលកើតពីខួស ។

**ឃ្នើស** គុ. ដែលងើស, ងក់, ងាល់: *ឃ្នើសចិត្ត* ។

**ឃ្នើសឃ្នង** គុ. ប្រឡើសប្រើស, ឈ្លើយឈ្លាន, ក្រហើន, ឈ្លានពាន, ច្រងើសឃ្នង: *មនុស្សឃ្នើសឃ្នង, សំដីឃ្នើសឃ្នង* (ម. ព. *ឃ្នង ២* គុ., *ច្រងើសឃ្នង* ផង) ។

**ឃ្មង់** ន. ឈ្មោះឈើមួយប្រភេទ ។

**ឃ្មុក** ន. ឈ្មោះវល្លិមួយប្រភេទសំបកក្រអូបសម្រាប់ធ្វើធូប: *សំបកឃ្មុក, ធូបឃ្មុក* ។

**ឃ្មុមៗ** កិ. វិ. ពាក្យសម្រាប់ចរើនពាក្យស៊ី, ពាក្យទំពាឲ្យឮកឡើង: *ស៊ីឃ្មុមៗ, ទំពាឃ្មុមៗ* គឺស៊ី ទំពាដោយមានអាហារពេញទូលក្នុងមាត់ ។



**ឃ្មាតខ្មី** កិ. ទំរើង, សង្វាតខ្លាំង: *ឃ្មាតខ្មីធ្វើការ* (ម. ព. *ខ្មីឃ្មាត* ផង) ។

**ឃ្មាមៗ** កិ. វិ. ពាក្យសម្រាប់ចរើនពាក្យទំពា, ពាក្យស៊ីឲ្យឮកឡើង: *ទំពាឃ្មាមៗ, ស៊ីឃ្មាមៗ* គឺទំពា, ស៊ីដោយមានអាហារសាយពេញថ្ពាល់ទាំងពីរ ។

**ឃ្មឹក** ឬ. ពាក្យសម្រាប់ចរើនពាក្យក្រាស់ឲ្យវិសេសឡើង: *ក្រាស់ឃ្មឹក* ។

**ឃ្មឹល** គុ. ដែលឡើងសាច់ក្រាស់ក្អិល: *សាច់ឡើងឃ្មឹល, មុខឃ្មឹល* ។

**ឃ្មោះ** ន. គ្រឿងវាយដំប្រគំធ្វើដោយលង្ហិន, ដោះស្ពាន់ មានសណ្ឋានដូចគងធំ តែគ្មានដោះ: *គេវាយឃ្មោះឲ្យកូនប្រុសកូនស្រីចេញមក* (អាពាហ៍ពិពាហ៍) ។

**ឃ្មុំ ១** ន. ឈ្មោះសត្វល្អិតមួយប្រភេទក្នុងពួកភមរជាតិ មានទឹកផ្អែម សំណុំសម្រាប់ធ្វើក្រមួន: ឃ្មុំមានច្រើនយ៉ាង: *ឃ្មុំផ្ទឹត* មានមណ្ឌលសំបុកតូច សណ្ឋានស្រដៀងនឹងផ្ទឹតដែរ; *ឃ្មុំធំ* មានមណ្ឌលសំបុកធំ; *ឃ្មុំបូកគោ* មានមណ្ឌលសំបុកមូលក្រឡុលស្រដៀងនឹងបូកគោ ... ។

**ឃ្មុំ ២** ន. ឈ្មោះផ្កាមួយប្រភេទ សម្បុរខ្មៅ ឬ សក់មានខ្ទះចាប់យកឃ្មុំជាអាហារ: *ផ្កាឃ្មុំ* (ម. ព. *ផ្កា* ផង) ។

**ឃ្លង់** ន. ឈ្មោះរោគកើតអំពីឈាមចង្រៃចេញមកដល់សាច់ស្បែកខាងក្រៅឲ្យមានសម្បុរក្រហមជាំៗ ពកផុយហើយប្រែទៅជាដំបៅ, បើរឹតរក្សាដាក់ថ្នាំមិនត្រូវ ក៏នឹងចង្ការឲ្យកាត់ដៃជើងឡើង រហូតដល់កាច់ដៃជើងឲ្យក្រញិចក្រញ៉ង់, ឃ្លង់នេះហៅថា *ឃ្លង់ក្អិត* ។ មានឃ្លង់មួយយ៉ាង ហៅថា *ឃ្លង់រលួយ* ដែលចង្កាលឲ្យសាច់ស្បែករលួយធ្លាក់ខ្ទុះ មិនបានដល់កាច់ដៃជើងដូចឃ្លង់ក្អិតទេ ។ មានឃ្លង់មួយយ៉ាងទៀតហៅថា *ឃ្លង់ល្ពៅ* បណ្ដាលឲ្យស្បែកឡើងសតៗ នៅដៃជើង ឬ នៅមាត់, នៅថ្ពាល់, នៅក្បាល ។ មានឃ្លង់មួយយ៉ាងទៀត ហៅថា *ឃ្លង់ផែក* កើតនៅជើង, នៅដៃ បណ្ដាលឲ្យស្បែករឹងក្រាំង ដល់យូរទៅប្រែជារបកក្អុកផុយ ។ (មាន ព. ទ. បុ. ថា: *ឃ្លង់ផែកចែកកូនចែកចៅ ឃ្លង់ល្ពៅស្លាប់ទៅផុតចែក* មានន័យថា បើឪពុកកើតឃ្លង់ផែក ដល់មកកូន ឬចៅ គង់មានម្នាក់ណាមួយកើតឃ្លង់ផែកដូចឪពុក ឬ ជីតាដែរ ។ ថ្នាំព្យាបាលសង្កេតហើយ ឃើញពិតខ្លះទេខ្លះ) ។

**ឃ្លា** ន. ល្បះពាក្យ, ល្បះសេចក្ដី ដែលមានចំណុះត្រូវផុតឲ្យដាច់ ឲ្យឃ្លាត: *សេចក្ដីមួយឃ្លា, មើលពាក្យឲ្យដាច់ឃ្លា, សរសេរផុតឃ្លា* ។

**ឃ្លាត** កិ. ឃ្លាតចេញពីគ្នា ឬ ចែកពីគ្នាទៅឆ្ងាយ: *កន្ទុយឲ្យឃ្លាតពីគ្នា, បងប្អូនឃ្លាតគ្នាយូរឆ្នាំហើយ* ។

**ឃ្លាតឃ្លា** *គុ.* ឬ *កុ.* ឃ្លាតដាច់ស្រឡះ, ឃ្លាតឆ្ងាយដាច់សង្វែង (ម. ក. *ឃ្លា, ឃ្លាត* ផង) ។

**ឃ្លាតឃ្លៃ** *គុ.* ឬ *កុ.* (សំ. *វៃគ្ល* "ទៀល, ល្អិតល្អៃ, ល្វើងល្វើយ; ទុយលេក; ស្រពន់") បែកឃ្លាតចេញដាច់សង្វែង ឥតមានសង្ឃឹមថានឹងបានជួប ឬ បានត្រឡប់មកឃើញវិញ (ប្រើតែក្នុងកាព្យ) ។

**ឃ្លាន** *គុ.* (សំ. *គ្លាន*; បា. *គិលាន* "ឈឺ") ចង់បរិភោគអាហារ : *ឃ្លានបាយ* ។ (តាមកំណើតពាក្យ គួរតែសរសេរ *គ្លាន* ប៉ុន្តែធ្លាប់សរសេរ *ឃ្លាន* យូរណាស់ហើយក៏ត្រូវតែឲ្យនៅតាមទម្លាប់រៀងមក) ។

**ឃ្លាយតាត** *ន.* ឈ្មោះវល្លិ៍មួយប្រភេទសម្រាប់វេញខ្សែ : *ខ្សែឃ្លាយតាត* ។

**ឃ្លិប** *គុ.* (សរ. *ទ្វិប* ក. ច. *ឃ្លិប*) ដេរបំផាយ, ដេរបំ; រុំព័ទ្ធបន្ថែម ។

**ឃ្លុកៗ** *ន.* សូរឮដោយបុកត្រលុកវត្ថុប្រោង : *ឮសូរឃ្លុកៗ* ។

**ឃ្លុប** ១ *ន.* គន្លឹះសម្រាប់បិទបើកឲ្យទឹកហូរ : *ឃ្លុបទូក, ឃ្លុបកញ្ចាល់* ។

**ឃ្លុប** ២ *កុ.* ថ្ងៃឥតឆ្ងួញ គឺថ្ងៃដែលគួរហោរា កំណត់ឲ្យឈ្មោះតាមហោរាសាស្ត្រថា ថ្ងៃឥតជោគជ័យ, ឥតមង្គល ស្ញើ : *ថ្ងៃឃ្លុប* ។

**ឃ្លូប** *កុ.* ឬ *កិ. វិ.* ទន់ប្រមូលគ្នា : *ទន់ឃ្លូប, ធ្លាក់ឃ្លូប* ។ *ទំពាឃ្លូបៗ* ទំពាអាហារយ៉ាងឥតយ៉ាងរង ព្រោះឥតធ្មេញ (មនុស្សចាស់ដែលឥតធ្មេញ) ។

**ឃ្លៀង** *គុ.* ល្មៀងមិនចំគន្លង : *ពាក្យឃ្លៀង* ។

**ឃ្លៀងឃ្លាត** *គុ.* ឬ *កុ.* ល្មៀងឃ្លាតចេញ, ងាកចេញ, លាកចេញពីគ្នា : *សេចក្ដីឃ្លៀងឃ្លាត* ។

**ឃ្លៀច** *កុ.* មានសម្បុរស្រអាប់ដូចឆ្នាំងដី : *ក្របីឃ្លៀច* (និយាយចំពោះតែក្របី) ។ ដីដែលមានសម្បុរស្រដៀងនឹងឆ្នាំងដី ខ្មែរបុរាណហៅ *ដីឃ្លៀច* ដែរ, លុះចំណេរកាលតមក ខ្មែរហៅ *ដីស* ។

**ឃ្លេ** *ន.* ឈ្មោះឈើតោមមួយប្រភេទមានបន្លា សម្រាប់យកទឹកស្ងោរជ្រលក់ស្បូត ។

**ឃ្លេងឃ្លោង** *គុ.* ឬ *កិ. វិ.* ល្មៀងចុះល្មៀងឡើងច្រើនគង : *ខ្លួនត្រេតលេតឃ្លេងឃ្លោង* ។ *កុ.* ដែលអណ្ដែតអណ្ដូង, ដែលតោកតោរមិនទាន់នឹងមិនប្រាកដ : *ចិត្តឃ្លេងឃ្លោង* ។

**ឃ្លៃ** ១ *ន.* ឈ្មោះឫស្សីមួយពួកឥតបន្លា ដើមធំ ដូចឫស្សីស្រុក : *ឫស្សីឃ្លៃ* ។

**ឃ្លៃ** ២ *ប.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យឃ្លាត : *ឃ្លាតឃ្លៃ* (ម. ក. *ឃ្លាតឃ្លៃ*) ។



**ឃ្លោក** *ន.* ឈ្មោះវល្លិ៍មួយប្រភេទដាំនៅតាមស្រុកមានផ្លែជាបន្លែ; មាន ២ យ៉ាងគឺ មួយយ៉ាង មានផ្លែបែបដូចទឹក ហៅថា *ឃ្លោកសាយមៀវ*; មួយយ៉ាងទៀត មានផ្លែវែងៗ ហៅថា *ឃ្លោកវែង* ឬ ហៅត្រឹមតែ *ឃ្លោកៗ* ប៉ុណ្ណោះ ។

**ឃ្លោង** ១ *គុ.* ល្មៀងចុះល្មៀងឡើង : *ខ្លួនឃ្លោង* ។

**ឃ្លោង** ២ *ន.* ពាក្យសំដូចខ្ទួនសំដី : *ពាក្យឃ្លោង* ។

**ឃ្លុំ** ១ *កិ.* ពិណ្ឌប់រុំព័ទ្ធបិទបាំងកាយដោយចីវរ តាមវិន័យបញ្ញត្តិ : *លោកសង្ឃឃ្លុំចីវរ* ។ ជងបិទមាត់សត្វ : *យកខ្សែឃ្លុំមាត់គោ* ។

**ឃ្លុំ** ២ *ន.* ប្រដាប់សម្រាប់រុំព័ទ្ធមាត់សត្វជើង ៤ : *ឃ្លុំសេះ; ឃ្លុំមាត់ឆ្កែ* ។

**ឃ្លាំ** *គុ.* ឈរគន់កឹងមើលម្ដងៗ : *ទៅឃ្លាំមើល ក្រែងមនុស្សលួចប្លន់ស្រូវ* ។

**ឃ្លាំង** *ន.* ផ្ទះសម្រាប់ទុកដាក់ទ្រព្យរបស់ : *ឃ្លាំងប្រាក់, ឃ្លាំងទំនិញ, ឃ្លាំងសំពត់* ។ *ឃ្លាំងចំណេះ* គឺកន្លែងដែលតម្កល់គម្ពីរក្បួនច្បាប់ផ្សេងៗ ឬ សាលាសម្រាប់រៀនចំណេះផ្សេងៗ ។ មនុស្សដែលមានចំណេះវិជ្ជាច្រើន ក៏ហៅថា *ឃ្លាំងចំណេះ* ដែរ ។

**ឃ្វាំង** *គុ.* ឬ *កិ. វិ.* ដើរក្ដុស, ដើរត្រួសគ្នា : *ដើរឃ្វាំងគ្នា, ឃ្វាំងផ្លូវ, ឃ្វាំងសេចក្ដី* ។

**ឃ្វាចៗ** *គុ.* ពាក្យសម្រាប់បម្រើពាក្យដើរកែកជើងឲ្យច្បាស់ឡើង : *ដើរឃ្វាចៗ* គឺដើរដោយចំណេះម៉ៀចៗ ។

**ឃ្វាម** *ន.* ពាក្យក្លាយមកពីពាក្យ *ក្វាម* (ម. ក. *ក្វាម*) ។

**ឃ្វាយៗ** *គុ. វិ.* ដើរការជើងចូល : *ដើរឃ្វាយៗ, រត់ឃ្វាយៗ* ។

**ឃ្វាល** *គុ.* ចាំ, រក្សាសត្វចិញ្ចឹម : *ឃ្វាលគោ, ឃ្វាលក្របី, ក្មេងឃ្វាលក្របីដិតបិនមួយ* ។

**ឃ្វិច** *ន.* ឈ្មោះក្រូចមួយប្រភេទ សំបកស្ដើងជុំរ តាយបក ផ្លែប្រើបរិភោគជាចំណីណាស់ : *ក្រូចឃ្វិច* ។

**ឃ្វើង** *ន.* ឈ្មោះតាលមួយយ៉ាង ធំប្រហែលជាងតាល តោម : *តាលឃ្វើង, ស៊ីតាលអស់មួយឃ្វើង* (និយាយតាមទម្លាប់ដោយស្រុក, អ្នកខ្លះហៅ *ទ្រមោម* : *តាលមួយទ្រមោម*) ។

**ឃ្វើចៗ** *គុ. វិ.* ពាក្យនិយាយផ្សំនឹងពាក្យដើរឲ្យច្បាស់ឡើង : *ដើរឃ្វើចៗ* គឺដើរវៀចៗ ឃ្វើចៗ ព្រោះតែការជើងមានកើតដំបៅលោចជាដើម ។